Übersetzung eines Schreibens von: Uwe Kekeritz, MdB

An: Herbert Hainer, Adidas Group

Datiert: 04. Dezember 2014

អ៊ូវើ ខេខឺរីត្ស
Uwe Kekeritz
សមាជិកសភាសហព័ន្ធអាល្លឺម៉ង់

បាបារ៉ា ឡោះប៊ីលើ
Barbara Lochbihler
សមាជិកសភាអឺរ៉ុប

Uwe Kekeritz MdB, Platz der Republik 1, 11011 Berlin
Barbara Lochbihler, Rue Wiertz 60, B-1047 Brüssel

ជូនចំពោះលោក
ហ៊ែរប៊ើត ហៃន័រ
Herbert Hainer
Adidas Group
Adi-Dassler-Strasse 1
91074 Herzogenaurach

ប៊ែរលីន ថ្ងៃទី ៤ ធ្នូ ២០១៤

**កម្មវត្ថុ : ភាពពុំគាប់ប្រសើរនៅក្នុងវិស័យឧស្សាហកម្មវាយនភ័ណ្ឌកម្ពុជា**

លោកហៃន័រជាទីគោរព

តាំងពីខែធ្នូឆ្នាំ ២០១៣ មក អ្នកដេរនៅតាមរោងចក្រនៅកម្ពុជាបាននាំគ្នាធ្វើបាតុកម្មទាមទារអោយធ្វើការកែលំអចំពោះប្រាក់បៀវត្ស និងលក្ខខណ្ឌការងាររបស់គេនៅក្នុងវិស័យវាយនភ័ណ្ឌ។ នៅក្នុងសារលិខិតចំហរបស់លោកជូនចំពោះរដ្ឋាភិបាលកម្ពុជាចុះថ្ងៃទី ១៧ មករា ឆ្នាំ ២០១៤ នោះ លោកបានទាមទារអោយរកដំណោះស្រាយទំនាស់ដោយសន្តិវិធី ហើយអោយមានការគោរពដល់សហជីព និងអោយតម្លើងប្រាក់បៀវត្សអប្បបរមាជូនដល់កម្មករវាយនភ័ណ្ឌ។ យើងសូមសំដែងការគាំទ្រយ៉ាងជាក់ច្បាស់ចំពោះការខំប្រឹងប្រែងរបស់លោក ហើយក៏ចង់ជួយឧបត្ថម្ភដល់លោកនៅក្នុងរឿងនេះដែរ។

ដោយសារទំនាស់នេះនៅតែបន្តមានមកទល់នឹងសព្វថ្ងៃនេះ យើងសុំសួរលោកថា តើលោកវាយតម្លៃយ៉ាងណាដែរចំពោះផលនៃការអំពាវនាវរបស់លោក ដែលទាក់ទងទៅនឹងសភាពការណ៍របស់កម្មករទាំងនោះ និងតើសារលិខិតរបស់លោកនោះបាននាំមកនូវផលអ្វីខ្លះ? តើលោកមានបានធ្វើការទាក់ទងជាបន្ថែមទៀតជាមួយនឹងសហជីព ជាមួយម្ចាស់រោងចក្រ និងតំណាងខាងនយោបាយ

ឬទេ? ប្រសិនជាបានធ្វើ តើបានទទួលលទ្ធផលអ្វីខ្លះ? តើក្រុមហ៊ុន Adidas បានដកមេរៀនជាក់ស្តែងអ្វីចេញពីសភាពការណ៍នេះ? ហើយតើលោកជួយឧបត្ថម្ភអ្វីខ្លះដល់កម្មករនៅមូលដ្ឋាននោះ នៅក្នុងការតស៊ូ ដើម្បីអោយបានទទួលប្រាក់បៀវត្ស ដែលអាចធានាការផ្គត់ផ្គង់ជីវិតគេបាននោះ? តើក្រុមហ៊ុនរបស់លោកឥឡូវនេះបង់ប្រាក់បៀបត្សលើសពីកម្រិតអប្បបរមាហើយឬក៏យ៉ាងណា ហើយតើលោកបានធ្វើសកម្មភាពអ្វីខ្លះ ដើម្បីជម្រុញអោយអ្នកទទួលកិច្ចការពីលោកគេបង់ប្រាក់បៀវត្សអោយបានខ្ពស់ជាងមុន និងកែលំអដល់លក្ខខណ្ឌការងារអោយបានប្រសើរជាងមុននោះ?

នៅពេលធ្វើកូដកម្មនោះមានអ្នកដឹកនាំសហជីពមួយចំនួនត្រូវគេចាប់ខ្លួន។ តើលោកមានបានដឹងពីវាសនារបស់សមាជិកសហជីពទាំងនោះទេ និងតើលោកបានធ្វើអ្វីជាក់ស្តែងខ្លះ ដើម្បីជួយដល់អ្នកទាំងនោះ?

ប្រទេសនេះស្ថិតនៅក្នុងចំណោមទីតាំងផលិតកម្មធំជាងគេសម្រាប់ក្រុមហ៊ុនលោក។ ដូច្នេះហើយបានជាយើងស្នើសុំអោយលោកប្រើប្រាស់ឋានៈរបស់លោកជាអ្នកផ្តល់កិច្ចការដ៏សំខាន់នោះ ដើម្បីសម្រេចអោយបាននូវការកែលំអដល់វិស័យវាយនភ័ណ្ឌនៅកម្ពុជា។

Adidas ជាក្រុមហ៊ុនប្រពៃណីអាល្លឺម៉ង់ ដែលគេស្គាល់តាមរយៈយុទ្ធនាការផ្សាយពាណិជ្ជកម្ម និងយុទ្ធនាការជម្រុញភាពស្វ័យទ្រទ្រង់ធំៗនានា អាចនឹងបំពេញតាមគោលបំណងរបស់ខ្លួនបាននោះ លុះត្រាតែលក្ខខណ្ឌការងារសមរម្យ បទដ្ឋានសង្គមកិច្ច និងបរិដ្ឋាន ដែលគេអាចទទួលយកបាន ត្រូវបានទទួលការគោរពនៅគ្រប់ទីតាំងផលិតកម្មទាំងអស់របស់ក្រុមហ៊ុន។

ហេតុនេះហើយបានជាយើងសូមអោយលោកបោះជំហានយ៉ាងសកម្មឈ្ពោះទៅរកភាគីរដ្ឋាភិបាល ម្ចាស់សហគ្រាស អ្នកតំណាងកម្មករ និងអង្គការអន្តរជាតិ ដែលកំពុងធ្វើសកម្មភាពនានា ដើម្បីសម្រេចអោយបាននូវការកែលំអសភាពការណ៍អោយបានប្រសើរជាក់ច្បាស់ជាងមុន។

យើងត្រៀមខ្លួនជាស្រេចនឹងធ្វើការពិភាក្សាដោយផ្ទាល់ជាមួយលោក ដើម្បីនិយាយពីបញ្ហានេះ និងពិភាក្សាគ្នាអំពីប្រធានបទដូចបានលើកឡើងមកនេះ។ យើងចង់ដឹងពីចម្លើយតាមលិខិតរបស់លោក ហើយយើងត្រៀមខ្លួនជាស្រេចនឹងធ្វើការណាត់ជួបពិភាក្សាគ្នាជាមួយនឹងលោកនៅដើមឆ្នាំក្រោយនេះ។

ដោយគោរព

អ៊ូវើ ខេខីរីត្ស សមាជិកសភាសហព័ន្ធ　　　　　　　　　បាបារ៉ា ឡោះប៊ីលើ សមាជិកសភាអឺរ៉ុប